

១៤

# សិទ្ធិរបស់ជនជាប់ចោទជាអនីតិជន

## និយមន័យ

កុមារ (សំដៅដល់ជនមិនទាន់គ្រប់អាយុពេញវ័យ ឬអនីតិជន) គឺត្រូវបានកំណត់និយមន័យជាអន្តរជាតិថាជាមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ។

នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ អនីតិជន ដែលជាប់ចោទពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដូចគ្នាទៅនឹងនីតិជនដែរ។ ប៉ុន្តែអនីតិជនក៏ត្រូវការការការពារ និងការថែទាំពិសេសដែលស្របទៅតាមអាយុ ភាពចាស់ទុំ ព្រមទាំងការអភិវឌ្ឍផ្នែកបញ្ញា និងផ្នែកអារម្មណ៍របស់ពួកគេផងដែរ។



ចំណុចនេះបកស្រាយដោយភាពចាំបាច់ពិសេសសម្រាប់អាជ្ញាធររដ្ឋដើម្បីៈ

- ការពារការសន្មតទុកជាមុនថាគ្មានទោសរបស់ជនជាប់ចោទជាអនីតិជន តាមរយៈការផ្តល់នូវព័ត៌មានអំពីការអភិវឌ្ឍរបស់កុមារទៅកាន់អាជ្ញាធរ និងតួអង្គពាក់ព័ន្ធ។



- ជូនដំណឹងដល់អនីតិជនដោយផ្ទាល់ និងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានអំពីការចោទប្រកាន់ និងជំហាននីតិវិធីលើពួកគេ និងកាន់តែប្រសើរ បើការជូនដំណឹងនោះអាចធ្វើបានតាមរយៈឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់។
- ផ្តល់ឱ្យជនជាប់ចោទជាអនីតិជននូវជំនួយដោយឥតគិតថ្លៃ និងសមរម្យ ដើម្បីរៀបចំការពារក្តីរបស់ពួកគេ។
- ការពារសិទ្ធិរបស់អនីតិជនក្នុងការមិនត្រូវបានបង្ខិតបង្ខំឱ្យផ្តល់សក្ខីកម្ម ឬសារភាពពីពិរុទ្ធភាពរបស់ពួកគេ។
- នាំជនជាប់ចោទជាអនីតិជនមកបង្ហាញខ្លួនចំពោះមុខអាជ្ញាធរ ឬស្ថាប័នតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង "ដោយមិនមានការពន្យារពេល"។
- អនុវត្តដំណើរការនីតិវិធីមួយ ដែលមានបរិយាកាសអាចអនុញ្ញាតឱ្យជនជាប់ចោទជាអនីតិជនបានយល់ ចូលរួម និងគោរពគោលការណ៍ស្មើភាពគ្នា។
- ផ្តល់ឱ្យអនីតិជននូវអ្នកបកប្រែដោយឥតគិតថ្លៃ ប្រសិនបើអនីតិជនមិនចេះភាសា ដែលប្រើប្រាស់ក្នុងសវនាការ។
- ធានាថាឯកជនភាពរបស់អនីតិជនត្រូវបានគោរពនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី។ សវនាការរបស់អនីជនត្រូវតែដំណើរការជាអសាធារណៈស្របតាមវិធានទូទៅ។
- គោរពសិទ្ធិរបស់ជនជាប់ចោទជាអនីតិជនក្នុងការទទួលបានសវនាការនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី។



- បង្ការការដកហូតសេរីភាពរបស់អនីតិជនតាមអំពើចិត្ត និងខុសច្បាប់នៅគ្រប់ពេលវេលាទាំងអស់។
- ហាមឃាត់ការកាត់ទោសប្រហារជីវិត និងការដាក់ពន្ធនាគារអស់មួយជីវិត ដោយគ្មានលទ្ធភាពដោះលែង។



រដ្ឋក៏ត្រូវបានលើកទឹកចិត្តឱ្យបង្កើតប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនីតិជនសមស្រប ដោយមានច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័ន ដែលអនុវត្តជាពិសេសចំពោះអនីតិជន ដើម្បីធានាថា អនីតិជនទទួលបានការប្រព្រឹត្តចំពោះខ្លួនក្នុងស្ថានភាពមួយ ដែលស្របទៅនឹងអាយុរបស់ពួកគេ។ រដ្ឋត្រូវកំណត់អាយុអប្បបរមាពីការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់ជនជាប់ចោទជាអនីតិជន ហើយអនីតិជន ដែលមានអាយុក្រោមការកំណត់នេះ មិនអាចទទួលខុសត្រូវព្រហ្មទណ្ឌឡើយ និងផ្តល់អាទិភាពដល់វិធានការជំនួសចំពោះដំណើរការនីតិវិធីព្រហ្មទណ្ឌសម្រាប់ជនជាប់ចោទជាអនីតិជន ។

# ក្របខណ្ឌច្បាប់

## ច្បាប់អន្តរជាតិ



មាត្រា ១៤(៤) នៃសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា "នីតិវិធីអនុវត្តចំពោះយុវជន យុវនារី ដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ" ទទួលស្គាល់ និងតម្រូវឱ្យការពារសិទ្ធិរបស់អនីតិជនដូចមានចែងក្នុងមាត្រា ២៤ (១) នៃកតិកាសញ្ញានេះដែរ។ អនុសញ្ញាស្តីពីសិទ្ធិកុមារក៏បញ្ញត្តដាក់លាក់សម្រាប់ការការពារអនីតិជនក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌផងដែរ។

## ច្បាប់ជាតិ

មាត្រា ៣១ និងមាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញចែងយ៉ាងច្បាស់លាស់ថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដូចដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ [...] ។" ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាមានបញ្ញត្តិជាច្រើនទាក់ទងនឹងជនជាប់ចោទជាអនីតិជន។ ហើយច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ ក៏បានកំណត់នូវវិធានជាក់លាក់សម្រាប់ការអនុវត្តចំពោះជនជាប់ចោទជាអនីតិជន។




## សារសំខាន់



អនីតិជនគឺជាប្រភេទមួយនៃបុគ្គលដែលងាយរងគ្រោះបំផុត ដោយសារតែអាយុ និងការអភិវឌ្ឍរបស់ពួកគេ។ ឧត្តមប្រយោជន៍ និងសុខុមាលភាពរបស់ពួកគេត្រូវតែជាការពិចារណាចម្បងនៅគ្រប់វិធានការទាំងអស់ រួមទាំងវិធានការ ដែលអនុវត្តដោយស្ថាប័នរដ្ឋ ឬសហគ្រាសឯកជនរបស់រដ្ឋ និងតុលាការ។

យុត្តិធម៌អនីតិជនដែលមានវិធាន និងវិធានការគ្រប់គ្រាន់ប្រព្រឹត្តចំពោះជនជាប់ចោទជាអនីតិជន ដោយពិចារណាទៅលើអាយុ ការអភិវឌ្ឍ និងភាពចាស់ទុំរបស់ពួកគេគឺមានសារសំខាន់។ ប្រការនេះធានាថាជីវភាពរបស់អនីតិជនដែលប្រព្រឹត្តបទល្មើស គឺមិនទទួលរងផលប៉ះពាល់អចិន្ត្រៃយ៍ អំពីអំពើដែលបានប្រព្រឹត្តនៅអាយុដែលពួកគេអាចនៅក្មេងពេកក្នុងការយល់ដឹង ឬក្មេងពេកក្នុងការគ្រប់គ្រងសកម្មភាពរបស់ខ្លួន។





យុត្តិធម៌អនីតិជន គឺជាមូលដ្ឋានក្នុងការលើកកម្ពស់ស្មារតីនៃការគោរពសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់អនីតិជន ពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ និងធានាការធ្វើសមាហរណកម្មមកក្នុងសង្គមវិញដោយជោគជ័យ។

## ដែនកំណត់

យុត្តិធម៌អនីតិជនមិនមានការលើកលែង និងអនុវត្តចំពោះអនីតិជនទាំងអស់ដែលមានអាយុក្រោម ១៨ ឆ្នាំ នៅពេលដែលត្រូវបានចោទប្រកាន់ពីបទល្មើស ដើម្បីចៀសវាងការរើសអើង។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិតម្រូវថា រដ្ឋមិនត្រូវកម្រិតទៅលើការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងនីតិវិធីចំពោះអនីតិជន ដែលមានអាយុក្រោម ១៦ ឆ្នាំ ឬទាបជាងនេះ ឬដែលអនុញ្ញាតជាពិសេសឱ្យមានប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីប្រព្រឹត្តចំពោះអនីតិជនអាយុ ១៦ ឬ ១៧ ឆ្នាំ ដែលប្រព្រឹត្តបទល្មើស ដូចគ្នាទៅនឹងនីតិជនផងដែរ ដើម្បីចៀសវាងពីការរើសអើងទៅលើអនីតិជនទាំងនោះ។



September 2022

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA